YUNNAN DAILY PRESS GROUP
No.192

# ប្រទេសចិន-ខេត្តយូនណាន

រស្មីកម្ពុជា ប្រចាំថ្ងៃ

khmerlight@163.com
english.yunnan.cn

ឆ្នាំទី27 លេខ7995 ថ្ងៃព្រហស្បតិ៍ ទី02 ខែសីហា ឆ្នាំ2019

## ប្រទេសកម្ពុជានឹងចាត់បញ្ជូនគណៈប្រតិភូទៅចូលរួមពិព័រណ៍នាំចូលចិនអន្តរជាតិលើកទី២

ពេលថ្មីៗនេះលោក ស៊ាង ថៃ អនុរដ្ឋលេខាធិការនិងជាអ្នកនាំពាក្យក្រសួងពាណិជ្ជកម្មកម្ពុជាបានផ្តល់បទសម្ភាសន៍ជាមួយអ្នកកាសែតថា ឆ្នាំនេះកម្ពុជានឹងចាត់បញ្ជូនគណៈប្រតិភូទៅចូលរួមពិព័រណ៍នាំចូលចិនអន្តរជាតិលើកទី២។

លោកមានប្រសាសន៍ថា ប៉ុន្មានឆ្នាំនេះ ទំហំពាណិជ្ជកម្មរវាងប្រទេសកម្ពុជានិងចិនបាន និងកំពុងកើនឡើងជាបន្តបន្ទាប់ហើយបានបង្ហាញពីអនាគតដ៏ភ្លឺស្វាង ។ ប្រទេសចិនបាននាំចូលកសិផលច្រើនពីប្រទេសកម្ពុជាដែលបានផ្តល់ផលប្រយោជន៍ដល់កសិករខ្មែរ ។ ពាណិជ្ជកម្មរវាងភាគីទាំងពីរមិនគ្រាន់តែបានផ្តល់ឱកាសការងារដល់ប្រជាជនខ្មែរប៉ុណ្ណោះទេ ថែមទាំងបានជួយបង្កើនចំណូលរបស់ប្រជាជនខ្មែរទៀតផង ។ សព្វថ្ងៃប្រទេសចិនបានក្លាយទៅជាទីផ្សារនាំចេញអង្ករធំជាងគេរបស់ប្រទេសកម្ពុជា ។

លោកបានបញ្ជាក់ថា ឆ្នាំទៅកម្ពុជាបានចាត់បញ្ជូនគណៈប្រតិភូទៅចូលរួមពិព័រណ៍នាំចូលចិនអន្តរជាតិលើកទី១ ។ ពិព័រណ៍នេះបានបង្ហាញជូនពិភពលោកទាំងមូលនូវឆន្ទៈរបស់ប្រទេសចិនអំពីការបើកទូលាយទីផ្សារចំពោះពិភពលោក និងការជំរុញពាណិជ្ជកម្មពហុភាគី ។ លោកបន្តទៀតថា ការចូលរួមពិព័រណ៍នាំចូលចិនអន្តរជាតិជាឱកាសមាសសម្រាប់ផ្សព្វផ្សាយពីផលិតផលខ្មែរចំពោះប្រទេសចិន និងបណ្តាប្រទេសនានាលើពិភពលោក ។

លោកសង្កត់ធ្ងន់ថា ពាណិជ្ជកម្មកម្ពុជា-ចិនដែលកំពុងរីកចម្រើនយ៉ាងឆាប់រហ័សនោះជាសក្ខីភាពមួយអំពីទំនាក់ទំនងកាន់តែស្អិតល្មួតរវាងប្រទេសចិននិងអាស៊ាន ។ តាមទិន្នន័យពាក់ព័ន្ធបានឱ្យដឹងថានៅឆមាសទី ១ នៃឆ្នាំ ២០១៩ នេះទំហំពាណិជ្ជកម្មនាំចេញនាំចូលរវាងប្រទេសចិន និងអាស៊ានបានកើនឡើងដល់១,៩៨ទ្រីលានយាន់ប្រាក់ចិន ស្មើនឹង១៣,៥ភាគរយ នៃទំហំនាំចេញនាំចូលសរុបរបស់ប្រទេសចិន ៕

-ព័ត៌មានបន្ថែម:ពិព័រណ៍នាំចូលចិនអន្តរជាតិលើកទី២ នឹងរៀបចំនៅមជ្ឈមណ្ឌលសន្និសីទនិងពិព័រណ៍អន្តរជាតិក្រុងសៀងហៃក្នុងអំឡុងពេលពីថ្ងៃទី៥ដល់ទី ១០ ខែវិច្ឆិកា ឆ្នាំ ២០១៩ ៕ **(ស៊ីនហួចិន)**

## សិល្បករសិល្បការិនីខ្មែរសម្តែងកម្មវិធីសិល្បៈនៅមណ្ឌលស្វយ័តឈូស្យុងនៃខេត្តយូនណាន



*សិល្បការិនីខ្មែរកំពុងរាំរបាំប្រពៃណីខ្មែរ " របាំជូនពរ " (ស៊ីនហួចិន)*

នៅថ្ងៃទី២៤ ខែកក្កដា ទិវាវប្បធម៌សម្លៀកបំពាក់ជនជាតិភាគតិចឆ្នាំ២០១៩ និងកម្មវិធីសម្តែងសិល្បៈប្រទេសអាស៊ីអាគ្នេយ៍ចំនួន៥ "សម្លៀកបំពាក់ដ៏ស្រស់ស្អាតខេត្តយូនណានដ៏ចម្រុះពណ៌" បានរៀបចំនៅមណ្ឌលស្វយ័តជនជាតិយីឈូស្យុងខេត្តយូនណាន ប្រទេសចិន។ កម្មវិធីនេះបានបង្ហាញពីសម្លៀកបំពាក់ដ៏ស្រស់ស្អាតរបស់ជនជាតិភាគតិចផ្សេងៗក្នុងប្រទេសចិន។ មិនតែប៉ុណ្ណោះ សិល្បករសិល្បការិនីដែលមកពីប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាមបានសម្តែងកម្មវិធីសិល្បៈដែលប្រកបដោយលក្ខណៈពិសេសនៃតំបន់អាស៊ីអាគ្នេយ៍៕

## ចំនួនអ្នកសិក្សាស្រាវជ្រាវបច្ចេកទេសថ្មីរបស់ប្រទេសចិនជាប់លំដាប់លេខ១លើពិភពលោកក្នុងរយៈពេល៦ឆ្នាំជាប់ៗគ្នា



*នៅថ្ងៃទី ១៧ ខែ កក្កដា អ្នកសិក្សាស្រាវជ្រាវកំពុងធ្វើតេស្តអំពីការទាញសម្ភារប្លាស្ទិក ក្នុងបន្ទប់ពិសោធន៍នៃមជ្ឈមណ្ឌលសិក្សា ស្រាវជ្រាវ និងពិសោធន៍បរិស្ថាន ធម្មជាតិ ក្នុងតំបន់ស្វយ័តជនជាតិវុយហ្គ៉ូរ ស៊ីនជាំង ប្រទេសចិន(ស៊ីនហួចិន)*

តាមរបាយការណ៍អំពីសមិទ្ធផលអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គម ដើម្បីអបអរសាទរខួបលើកទី៧០ នៃការបង្កើតប្រទេសចិនថ្មីដែលប្រកាសដោយអាជ្ញាធរជាតិស្ថិតិចិនបានឱ្យដឹងថា នៅឆ្នាំ ២០១៨ ប្រទេសចិនមានអ្នកសិក្សាស្រាវជ្រាវបច្ចេកទេសថ្មី៤,១៩លាននាក់ ស្មើនឹង ៦,២ដងនៃឆ្នាំ ១៩៩១ ។ នៅឆ្នាំ២០១៣ចំនួនអ្នកសិក្សាស្រាវជ្រាវចិនបានកើនឡើងច្រើនជាងប្រទេសអាមេរិក ហើយបានជាប់លំដាប់លេខ១ លើពិភពលោកក្នុងរយៈពេល ៦ឆ្នាំជាប់ៗគ្នា ។

តាមរបាយការណ៍នេះ បានឱ្យដឹងថា ថវិកានៃការសិក្សាស្រាវជ្រាវរបស់ប្រទេសចិនបាននិងកំពុងកើនឡើងយ៉ាងឆាប់រហ័ស ។ នៅឆ្នាំ២០១៨ប្រទេសចិនបានផ្តល់ថវិកា១.៩៦៥.៧០០លានយាន់សម្រាប់ធ្វើការសិក្សាស្រាវជ្រាវអំពីបច្ចេកទេសថ្មី ស្មើនឹង ១៣៨ដងនៃឆ្នាំ ១៩៩១ ។ នៅឆ្នាំ ២០១៤ថវិកានៃការសិក្សា ស្រាវជ្រាវរបស់ប្រទេសចិនបានកើនឡើងដល់កម្រិតជាង២ភាគរយនៃ GDP ជាលើកដំបូងហើយបានកើនឡើង ដល់កម្រិត ២,១៨ភាគរយ នៃ GDP នៅ ឆ្នាំ២០១៨ ដែលមានកម្រិតខ្ពស់ជាងកម្រិតមធ្យមនៃប្រទេសចំនួន ១៥ ដែលជាសមាជិកនៃសហភាពអឺរ៉ុប ។ ប្រទេសចិនបានក្លាយទៅជាប្រទេសដែលផ្តល់ថវិកាសិក្សា ស្រាវជ្រាវច្រើន ជាងគេទី ២ លើពិភពលោក បន្ទាប់ពីប្រទេសអាមេរិក ។ ម្យ៉ាងទៀតប្រទេសចិនបាន និងកំពុងកាន់កាប់កម្មសិទ្ធិបញ្ញា កាន់តែច្រើន។ តាមរបាយការណ៍នេះបានឱ្យដឹងថា នៅឆ្នាំ ២០១៨ការស្នើសុំ និងផ្តល់កម្មសិទ្ធិបញ្ញា patent របស់ប្រទេសចិនមានចំនួន៤,៣២៣លាន និង ២,៥៤៨លាន ស្មើនឹង ៨៦ ដង និង ៩៨ដងនៃឆ្នាំ ១៩៩១ ៕ **(ស៊ីនហួចិន)**

## អ្នកនិពន្ធចិន និងអាស៊ានរួមគ្នាពិគ្រោះពិភាក្សាអំពី "ផ្លូវសូត្រអក្សរសិល្ប៍ថ្មី"

នៅថ្ងៃទី២៤ ខែកក្កដា វេទិកាអក្សរសិល្ប៍ចិន-អាស៊ាន លើកទី១ ដែលរៀបចំដោយសមាគមអ្នកនិពន្ធចិនបានបើកសម្ពោធនៅក្រុងគុនមីង។ អ្នកនិពន្ធ៥០រូប ដែលមកពីប្រទេសថៃ សិង្ហបុរី ម៉ាឡេស៊ី ឡាវ វៀតណាមនិងចិនជាដើមបានអញ្ជើញចូលរួមក្នុងវេទិកានេះ។

វេទិកានេះរៀបចំក្រោមប្រធានបទ "ខ្សែក្រវាត់មួយនិងផ្លូវមួយ: ផ្លូវសូត្រអក្សរសិល្ប៍ថ្មី"។ អ្នកនិពន្ធចិន និងបរទេសបានចូលរួមកម្មវិធីពិគ្រោះពិភាក្សានិងផ្លាស់ប្តូរគ្នារយៈពេល២ ថ្ងៃអំពីចំណងជើងសំខាន់ចំនួន ២ គឺ"ផ្លូវអក្សរសិល្ប៍របស់ខ្ញុំ: តាមរយៈស្នាដៃមួយ" និង"ក្រអៅបេះដូងវាសនា និងអនាគត" ។

លោកយ៉ាន ជីងម៉េង អនុប្រធានសមាគមអ្នកនិពន្ធចិនបានថ្លែងសុន្ទរកថាក្នុងពិធីបើកវេទិកានេះថាប្រទេសចិននិងអាស៊ីអាគ្នេយ៍មានទឹកដីនៅជាប់នឹងគ្នា និងមានវប្បធម៌ស្រដៀងគ្នា។ ស្នាដៃអក្សរសិល្ប៍ល្បីឈ្មោះរបស់ប្រទេសចិន "សុបិនផ្ទះក្រហម" បានពិពណ៌នាអំពីរតនវត្ថុដែលត្រូវនាំយកពីប្រទេសថ្វាចំណែកគំនូរលើជញ្ជាំងដ៏ស្អាតប្រណីតនៅតំបន់អង្គរនៃប្រទេសកម្ពុជាបានកត់ត្រានូវប្រវត្តិសាស្ត្រដែលជនជាតិចិននិងខ្មែររួមរស់នៅជាមួយគ្នា។ លោកសង្ឃឹមថាវេទិកានេះនឹងអាចរួមចំណែកក្នុងការបង្កើនការផ្លាស់ប្តូរនិងពង្រឹងចំណងមិត្តភាពរវាងអ្នកនិពន្ធនៃបណ្តាប្រទេសនានា ហើយជំរុញការបកប្រែស្នាដៃអក្សរសិល្ប៍ទៅវិញទៅមក និងកសាងមូលដ្ឋានគ្រឹះផ្នែកប្រជាមតិសម្រាប់ការពង្រឹងចំណងមិត្តភាពរវាងប្រទេសចិននិងអាស៊ាន៕ **(ស៊ីនហួចិន)**

## ផ្កាយូនណានតុបតែងស្រុកខ្មែរ

ផ្កាកុលាបរបស់ខេត្តយូនណានបានត្រូវដឹកជញ្ជូនពីក្រុងគុនមីងនៃខេត្តយូនណានទៅដល់រាជធានីភ្នំពេញនៃប្រទេសកម្ពុជាដោយចំណាយពេលមិនដល់ ២៤ ម៉ោង ។ លោក ហ្វូ ឆាវ នាយកក្រុមហ៊ុនផ្កាទានវ៉ាង ក្រុងគុនមីងខេត្តយូនណានបានបញ្ជាក់ថា នេះជាល្បឿនលឿនជាងគេដែលនាំចេញផ្កាស្រស់ពីក្រុងគុនមីងទៅប្រទេសកម្ពុជា ។ ក្រុមហ៊ុនយើងខ្ញុំមានលក្ខណសម្បត្តិនាំចេញនាំចូលផ្កាស្រស់ហើយអាចដឹកជញ្ជូនផ្កាស្រស់ពីប្រទេសចិនទៅប្រទេសកម្ពុជាដោយផ្ទាល់តាមផ្លូវអាកាសចរណ៍ ។

ប៉ុន្មានឆ្នាំនេះ ក្រុមហ៊ុនទានវ៉ាងបានក្តាប់ជាប់នូវឱកាសដ៏ល្អដើម្បីពង្រីកអាជីវកម្មផ្កាស្រស់នៅទីផ្សារនៃតំបន់អាស៊ីអាគ្នេយ៍ ។ បន្ទាប់ពីក្រុមហ៊ុនផ្កាទានវ៉ាងសាខាកម្ពុជាត្រូវបានបង្កើតនៅឆ្នាំ២០១៤ រៀងមក ក្រុមហ៊ុនបានសម្រេចកំណើនពាណិជ្ជកម្ម២០ភាគរយ ជារៀងរាល់ឆ្នាំ ។ គិតជាមធ្យមផ្កាស្រស់ដែលនាំចេញពីខេត្តយូនណានទៅកម្ពុជាមានចំនួនលើសពី១០លានទងក្នុងរយៈពេលមួយឆ្នាំ។

តាមស្ថិតិពីក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទកម្ពុជា បានឱ្យដឹងថាផ្កាស្រស់ដែលប្រើប្រាស់នៅប្រទេសកម្ពុជាមានតែ៣០ភាគរយ ត្រូវដាំក្នុងស្រុកភាគច្រើនគឺត្រូវនាំចូលពីបរទេស ។ ក្រុមហ៊ុន ទានវ៉ាង ជាក្រុមហ៊ុនទី១ ដែលធ្វើអាជីវកម្មនាំចេញផ្កាស្រស់ពីប្រទេសចិនទៅប្រទេសកម្ពុជា ។ លោកភឿង រិទ្ធិ អ្នកទទួលខុសត្រូវនៃក្រុមហ៊ុនទានវ៉ាងសាខាកម្ពុជាបានប្រាប់អ្នកកាសែតថា ដោយសារផ្កាស្រស់ចិនមានផ្កាធំគុណភាពល្អ និងអាចរីកបានយូរជនជាតិខ្មែរចូលចិត្តប្រើផ្កាស្រស់របស់ចិន ។

លោកភឿង រិទ្ធិ បានបន្តទៀតថានៅឆ្នាំ ២០១៤ខ្ញុំបានចូលធ្វើការក្នុងក្រុមហ៊ុននេះ ។ កាលនោះ ខ្ញុំមិនចេះលក់ទំនិញហើយក៏មិនចេះធ្វើការគ្រប់គ្រងក្រុមហ៊ុនទេ ដូច្នេះ ខ្ញុំចាប់ផ្តើមធ្វើការបណ្តើររៀនបណ្តើរ ។ ខ្ញុំបានចំណាយពេល៥ឆ្នាំហើយឡើងឋានៈពីអ្នកជញ្ជូនទំនិញធម្មតាម្នាក់ទៅជានាយកក្រុមហ៊ុន ។ លោក ហ្វូ ឆាវ បានបញ្ជាក់ថា យើងមិនគ្រាន់តែត្រូវធ្វើអាជីវកម្មឱ្យបានល្អប៉ុណ្ណោះទេហើយត្រូវសហការគ្នាជាមួយអ្នកស្រុកក្នុងតំបន់ដើម្បីសម្រេចនូវការឈ្នះ-ឈ្នះ ។

-តួលេខអំពីអាជីវកម្មផ្កាស្រស់ខេត្តយូនណាន

នៅឆ្នាំ២០១៨ ខេត្តយូនណានបានដាំផ្កាស្រស់ដែលមានទំហំសរុប១១,៤ម៉ឺនហិកតាកើនឡើង ៩,៧ ភាគរយ មានទំហំពាណិជ្ជកម្មសរុប ៥២.៥៩០ លានយាន់កើនឡើង៤,៥ភាគរយមានសហគ្រាសផ្កាស្រស់ចំនួន ២.៣១៦កើនឡើង ៨,៣ភាគរយ ។ខេត្តយូនណាន ដណ្តើមបានទីផ្សារផ្កាស្រស់៧០ភាគរយក្នុងទីក្រុងធំនិងមធ្យមចំនួនជាង៨០ ក្នុងប្រទេសចិន ៕



*កសិដ្ឋានដាំផ្កាស្រស់របស់បណ្ឌិត្យសភាកសិកម្មខេត្ត យូនណានក្នុងស្រុកជីវស៊ី ក្រុង យូស៊ី (ដោយយ៉ាង ជឹង)*

**ដោយយូ ជាំងនីង**